### ***ប្រព័ន្ធកសិកម្មចំរុះកំពស់***

នៅក្នុងជំរើសនេះគេដាំដើមឈើសំរាប់ជាគ្រឿងសំណង់និងសំរាប់ផ្តល់ផលិតផលមិនមែនឈើ នៅតាមចន្លោះដីទំនេរពីដំណាំសិកម្ម ដោយពុំគិតគូរពីជួរបន្ទាត់ ( សូមមើលចំណុច ៨.២.១ ផងដែរ) ។



### ***សូមប្រើប្រាស់ទំព័របន្ថែម និង ឧបសម្ព័ន្ធនានាដូចខាងក្រោមៈ***

ឧបសម្ព័ន្ធទី ១: ការរជ្រើសរើសប្រភេទឈើ

ឧបសម្ព័ន្ធទី ២: លទ្ធកម្មគ្រាប់ពូជ

ឧបសម្ព័ន្ធទី ៣: ការងារនៅថ្នាលបណ្តុះកូនឈើ

ឧបសម្ព័ន្ធទី ៤: ការងារនៅចំការដាំឈើ

ឧបសម្ព័ន្ធទី ៥: ការថែរក្សាចំការឈើដាំ

ឧបសម្ព័ន្ធទី ៦: គោលការណ៍ណែនាំសំរាប់ការធ្វើសេចក្តីសំរេចចិត្តក្នុងការស្តារដីព្រៃឡើងវិញ

ឧបសម្ព័ន្ធទី ៨: វិធីសាស្រ្តក្នុងការជ្រើរើសប្រភេទឈើសំរាប់ដាំដើម្បីកាត់បន្ថយភាពក្រីក្រ

ឧបសម្ព័ន្ធទី ១០: ប្រភេទឈើមួយចំនួនដែលផ្តល់ផលិតផលបន្ថែមក្រៅពីឈើ

ទំព័របន្ថែមទី១: ការគណនាតំរូវការគ្រាប់ពូជឈើ

## ៩. ការដាំឈើនៅលើដីសាធារណៈ

ការងារដាំដើមឈើតាមរបៀបនេះអាចធ្វើឡើងតាមរយៈសហគមន៍ ( សហគមន៍ព្រៃឈើ) រដ្ឋាភិបាល និងទីភ្នាក់ងារអភិវឌ្ឍន៍នានា ។ អង្គការក្រៅរដ្ឋាភិបាលខ្លះដូចជា អង្គការមូប់បៃតង អង្គការសន្តិសេនា អង្គការ LWF សមាគមន៍ (Lion Club) និង ផ្នែកឯកជននានា ( ក្រុមហ៊ុនថ្នាំជក់អង់គ្លេសអាមេរិកាំងនៅកម្ពុជា) សុទ្ធតែជាដៃគូរដ៏ល្អសំរាប់សហគមន៍មូលដ្ឋានក៏ដូចជារដ្ឋាភិបាល ក្នុងការងារដាំដើមឈើតាមវិធីសាស្រ្តនេះ ។

សំរាប់ការអនុវត្តគេអាចដាំដើមឈើមួយជួរ ឬច្រើនជួរ តាមសងខាងផ្លូវថ្នល់ សងខាងព្រែកជីក តាមជើងទំនប់ ដាំជាជ្រុំតូចៗនៅក្នុងសាលារៀន ក្នុងទីធ្លាវត្តអារាម ដាំនៅជុំវិញមាត់ត្រពាំង បឹង សំរាប់ធ្វើជាអុស ចំណីសត្វ និងផ្លែឈើ ។ល។ នៅទីនេះ គេអាចអនុវត្តបច្ចេកទេសដាំដើមឈើចំរុះកំពស់ ឬវិធីសាស្ត្រមីយ៉ាវ៉ាគី ។

ប្រភេទឈើដែលនិយមប្រើប្រាស់: ភាគច្រើននៃជីសាធារណៈជាប្រភេទដីត្រងោល។ ប្រភេទឈើដែលផលិត ផលអនុផលក្រៅពីឈើ គួយកមកដាំនៅទីនេះ។ ទោះជាយ៉ាងនេះក្តី ត្រូវប្រើប្រាស់ប្រភេទដែលចូលចិត្តពន្លឺថ្ងៃ ហើយធន់ទ្រាំទៅនឹងការកាត់ជាញឹកញាប់ (សំរាប់ធ្វើអុសដុត) ឬធន់ទ្រាំទៅនឹងការច្រឹបស៊ីដោយហ្វូងសត្វពាហន (គោ ក្របី ចៀម ពពែ) ។

***សូមប្រើប្រាស់ទំព័របន្ថែម និង ឧបសម្ព័ន្ធនានាដូចខាងក្រោម:***

ឧបសម្ព័ន្ធទី ១: ការជ្រើសរើសប្រភេទឈើ

ឧបសម្ព័ន្ធទី ២: លទ្ធកម្មគ្រាប់ពូជ

ឧបសម្ព័ន្ធទី ៣: ការងារនៅថ្នាលបណ្តុះកូនឈើ

ឧបសម្ព័ន្ធទី ៤: ការងារនៅចំការដាំឈើ

ឧបសម្ព័ន្ធទី ៥: ការថែរក្សាចំការឈើដាំ

ឧបសម្ព័ន្ធទី ៨: វិធីសាស្ត្រក្នុងការជ្រើសរើសប្រភេទឈើសំរាប់ដាំដើម្បីកាត់បន្ថយភាពក្រីក្រ

ឧបសម្ព័ន្ធទី ៩: ចំណង់ចំណូលចិត្តរបស់កសិករក្នុងការជ្រើសរើសប្រភេទឈើសំរាប់ដាំ

ឧបសម្ព័ន្ធទី ១០: ប្រភេទឈើមួយចំនួនដែលផ្តល់ផលិតផលបន្ថែមក្រៅពីឈើ

ទំព័របន្ថែមទី១: ការគណនាតំរូវការគ្រាប់ពូជឈើ